ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

**មាតុភូមិនិវត្តន៍របស់ពលករិនីខ្មែរ៣នាក់ ពីប្រទេសម៉ាឡេស៊ី**

******

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ**៣នាក់៖**

១- ពលការិនី ឈ្មោះ **ផ.ច** អាយុ២៨ឆ្នាំ មានស្រុកកំណើតនៅខេត្តត្បូងឃ្មុំ បានទៅធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី ពីថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជាឈ្មោះ 168 Manpower។ ដោយសារការងារលំបាក នាងបានទៅស្ថានទូត ដើម្បីស្នើជួយអោយបានត្រឡប់មកកម្ពុជាវិញ។ ដោយសាមីខ្លួនមិនស្គាល់ឈ្មោះនិងអាស័យដ្ឋានរបស់ថៅកែ ស្ថានទូតបានស្នើអោយក្រុមហ៊ុន168 Manpower ទិញសំបុត្រយន្តហោះ និងចេញថ្លៃបង់ពិន័យអោយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី សម្រាប់ពលការិនី។

ពលការិនី **ផ.ច** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី **០២** ខែ **វិច្ឆិកា** ឆ្នាំ **២០១៦** វេលាម៉ោង**១៦:០០**នាទី តាមជើងយន្តហោះលេខAK534 ។

២- ពលការិនី ឈ្មោះ **យ៉.ផ** អាយុ៤៧ឆ្នាំ មានស្រុកកំណើតនៅខេត្តកណ្តាល បានធ្វើដំណើរទៅម៉ាឡេស៊ីដោយខ្លួនឯង និងធ្វើការជាអ្នកលក់កាហ្វេ ពីថ្ងៃ០៦ ខែឧសភា ឆ្នាំ២០១៥។ ដោយទិដ្ឋាការផុតសុពលភាព ពលការិនីបានទៅស្ថានទូតនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ស្នើជួយអោយបានត្រឡប់មកកម្ពុជាវិញ។

៣- ពលការិនី ឈ្មោះ **វ៉.ធ** អាយុ២៦ឆ្នាំ មានស្រុកកំណើតនៅខេត្តព្រះវិហារ បានធ្វើដំណើរទៅម៉ាឡេស៊ីដោយខ្លួនឯង និងធ្វើការជាអ្នកបោសសំអាត ពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤។ ដោយទិដ្ឋាការផុតសុពលភាព ពលការិនីបានទៅស្ថានទូតនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៦ ស្នើជួយអោយបានត្រឡប់មកកម្ពុជាវិញ។

ពលការិនី **យ៉.ផ** និង **វ៉.ធ** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៥** ខែ **វិច្ឆិកា** ឆ្នាំ**២០១៦** វេលាម៉ោង**០៧:៥០**នាទីព្រឹក តាមជើងយន្តហោះលេខ AK536 ។

អំឡុងពេលរង់ចាំមកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ដល់ពលការិនី ទាំង**៣នាក់**ខាងលើផងដែរ៕

ភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ